# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបើកឆ្នាំសិក្សាថ្មីសម្រាប់អប់រំជំនឿ
# ភ្នំពេញថ្មី ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០
## ផ្តល់សក្ខីភាពអំពីជីវិតដើម្បីកសាងព្រះរាជ្យព្រះជាម្ចាស់

**អត្ថបទទី១៖ អេសាយ ៥,១-៧**

ខ្ញុំនឹកសង្ឃឹមថានឹងបានផ្លែទំពាំងបាយជូរល្អ តែហេតុដូចម្តេចបានជាចម្ការខ្ញុំ បង្កើតសុទ្ធតែផ្លែមិនល្អទៅវិញដូច្នេះ? អស ៥,៤

**អត្ថបទទី២៖ ភីលីព ៤,៦-៩**

សេចក្តីដែលបងប្អូនបានរៀន បានទទួល និងបានឮពីខ្ញុំ ហើយការអ្វីដែលបងប្អូនបានឃើញខ្ញុំធ្វើនោះ ចូរបងប្អូនប្រព្រឹត្តតាមទៅ។ ភីល ៤,៩

**ដំណឹងល្អ៖ ម៉ាថាយ ២១,៣៣-៤៣**

ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់នឹងដកព្រះរាជ្យចេញពីអ្នករាល់គ្នា ប្រគល់ទៅឲ្យសាសន៍មួយទៀត ដែលចេះបង្កើតផលសមស្របនឹងព្រះរាជ្យ។ មថ ២១,៤៣

បងប្អូនជាទីស្រឡាញ់!

កាលពីខ្ញុំនៅក្មេង ខ្ញុំបានទៅរៀនអប់រំជំនឿមួយសប្តាហ៍ម្តង ខ្ញុំមិនបានចាំមេរៀនណាមួយសោះ ប៉ុន្តែអ្វីដែលខ្ញុំចាំគឺលោកឪពុក និងបងស្រីដែលបានបង្រៀនខ្ញុំ។ ខ្ញុំចាំមានមីងម្នាក់ ដែលក្រុមខ្ញុំទៅផ្ទះរបស់គាត់មួយសប្តាហ៍ម្តង ដើម្បីអប់រំជំនឿទាក់ទងនឹងអត្ថសញ្ញានានា ខ្ញុំចាំបរិយាកាស សក្ខីភាព របៀបដែលបានស្រឡាញ់យើង របៀបដែលបានដឹកនាំយើង។ ខ្ញុំនិយាយដូច្នេះ ដើម្បីឲ្យយើងដែលជាគ្រូអប់រំជំនឿយល់ថា មេរៀនដែលយើងខិតខំបង្រៀនអស់ពីសមត្ថភាពក៏សំខាន់ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះគឺសក្ខីភាពដែលយើងផ្តល់ ទំនាក់ទំនងដែលយើងបានបង្កើតជាមួយបងប្អូនដែលបានមកទទួលការអប់រំជំនឿពីយើង។

ថ្ងៃនេះ ព្រះសហគមន៍បានឲ្យយើងស្តាប់អត្ថបទទីពីរ ដែលលោកប៉ូលបានសរសេរលិខិតផ្ញើទៅគ្រីស្តបរិស័ទថ្មីៗនៅក្រុងភីលីព ដោយថា "**សេចក្តីដែលបងប្អូនបានរៀន បានទទួល និងបានលឺពីខ្ញុំ ហើយការអ្វីដែលបងប្អូនបានឃើញខ្ញុំធ្វើនោះ ចូរបងប្អូនប្រព្រឹត្តតាមទៅ**"។ លោកប៉ូលបានធ្វើជាគ្រូអប់រំជំនឿ គាត់បានយកចិត្តទុកដាក់អប់រំជំនឿដល់គ្រីស្តបរិស័ទថ្មីៗនៅក្រុងភីលីព។ មុនគាត់ចេញធ្វើដំណើរទៅទីក្រុងមួយទៀត គាត់បានស្តាំដល់ពួកគេថា សេចក្តីដែលបានរៀនពីខ្ញុំដែលជាគ្រូអប់រំជំនឿ សេចក្តីដែលបានទទួល បានលឺពីខ្ញុំ ការអ្វីដែលបងប្អូនបានឃើញខ្ញុំធ្វើនោះសូមបងប្អូនប្រព្រឹត្តតាមទៅ។ មានន័យថា លោកប៉ូលដែលបានបង្រៀន បាននិយាយ បាន

បង្ហាញសក្ខីភាពនិងសកម្មភាពនានា យកគាត់ផ្ទាល់ខ្លួនជាគំរូសម្រាប់គ្រីស្តបរិស័ទ។ ហេតុនេះហើយ សម្រាប់យើងដែលជាគ្រូអប់រំជំនឿ សេចក្តីដែលយើងបង្រៀន សេចក្តីដែលយើងនិយាយ អ្វីដែលយើងប្រព្រឹត្តអាចទៅជាគំរូសម្រាប់ប្អូនៗរបស់យើង។ ពេលយើងលឺលោកប៉ូលនិយាយដូចនេះ យើងអាចគិតថាគាត់អួតខ្លួន គាត់ជាមនុស្សល្អ គាត់ជាគំរូសម្រាប់យើង ប៉ុន្តែពិតមែនត្រឹមត្រូវដោយសារគាត់មានព្រះជាម្ចាស់គង់នៅ។ គ្រូអប់រំជំនឿ មានព្រះជាម្ចាស់ មានព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅ យើងចាំរបៀបដែលព្រះយេស៊ូបាននិយាយច្រើនដងថា "**នៅពេលខ្ញុំទៅហើយ ខ្ញុំផ្ញើព្រះវិញ្ញាណដ៏វិសុទ្ធ**" ពេលយើងមានបញ្ហាមួយ ពេលយើងត្រូវបង្រៀនអ្វីខ្លះកុំព្រួយបារម្ភ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅជាមួយបងប្អូន ដើម្បីណែនាំឲ្យបងប្អូនអាចនិយាយបាន អាចផ្តល់សក្ខីភាពបាន អាចគាំទ្រនិងតស៊ូដោយមានកម្លាំងតទៅទៀតបាន។ ដូច្នេះបេសកកម្មដែលយើងទទួលជាគ្រូអប់រំជំនឿ មិនមែនជាបេសកកម្មដែលយើងទទួលពីយើងផ្ទាល់ខ្លួន តែជាបេសកកម្មដែលយើងទទួលពីព្រះសហគមន៍ ដោយដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅដើម្បីជួយបំភ្លឺយើង។ ថ្ងៃនេះ ព្រះសហគមន៍ជាមួយការិយាល័យអប់រំជំនឿនិងគម្ពីរ តាមរយៈលោកអភិបាលយើងសុំព្រះពរពីព្រះជាម្ចាស់ ដើម្បីឲ្យឆ្នាំថ្មីនេះយើងទទួលស្គាល់ថាយើងបានទទួលតួនាទីពីព្រះសហគមន៍ យើងមានព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅជាមួយយើង និងយើងអាចអួតខ្លួនបាន ដោយធ្វើជាគំរូសម្រាប់ប្អូនៗ។

ពេលលោកប៉ូលនិយាយ អំពីរបៀបដែលគាត់អប់រំជំនឿគាត់ថា "**អ្វីដែលបងប្អូនបានទទួល**" មានន័យថាលោកប៉ូលខិតខំចែករំលែក អំណោយទានដែលគាត់បានទទួលពីព្រះជាម្ចាស់។ ក្រោយមកគាត់និយាយថា "**អ្វីដែលបងប្អូនបានលឺ**" មានន័យថាមិនមែនតែអប់រំ មិនមែនតែចែករំលែក ប៉ុន្តែអ្វីៗទាំងអស់ដែលបានលឺពីខ្ញុំ មិនមែនតែមេរៀន គឺលឺអំពីជីវិតរបស់ព្រះយេស៊ូ លឺអំពីជីវិតព្រះសហគមន៍នានាដែលលោកប៉ូលបានបង្កើតមក លឺអំពីក្រុមគ្រីស្តទូតនៅទីក្រុងយេរូសាឡឹម។ ដោយសារនៅពេលនោះលោកប៉ូលនៅក្រុងភីលីព ឆ្ងាយពីទីក្រុងយេរូសាឡឹម លោកប៉ូលស្គាល់ក្រុមគ្រីស្តទូត ស្គាល់លោកសិលា លោកយ៉ាកុប លោកយ៉ូហាន... លោកប៉ូលអាចផ្តល់សក្ខីភាពអំពីអ្វីៗទាំងអស់ដែលគាត់បានឃើញ បានលឺពីសម័យព្រះយេស៊ូមកម្លេះ។ ចុងក្រោយលោកប៉ូលនិយាយថា "**អ្វីដែលបងប្អូនបានឃើញខ្ញុំធ្វើ**" លោកប៉ូលបានផ្តល់សក្ខីភាពអំពីរបៀបដែលគាត់អធិដ្ឋាន របៀបដែលគាត់សម្រុះសម្រួលបញ្ហានានា របៀបដែលលោកប៉ូលយកចិត្តទុកដាក់ធ្វើការចិញ្ចឹមជីវិត។ ប៉ុន្មានដងលោកប៉ូលបានប្រកាសថា "**ខ្ញុំមិនធ្វើអ្វីដោយទីពឹងលើបងប្អូន**" គាត់បានខិតខំដើម្បីចិញ្ចឹមជីវិតរបស់គាត់។ របៀបដែលលោកប៉ូលបានតស៊ូ គាត់បានទទួល

ការបៀតបៀនច្រើន គាត់បានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយច្រើនណាស់ ដើម្បីផ្តល់សក្ខីភាពអំពីអ្វីដែលគាត់បានធ្វើ។

ហេតុនេះហើយ គ្រូអប់រំជំនឿនៅពេលអប់រំជំនឿយកចិត្តទុកដាក់ត្រៀមមេរៀនយើងសម្រាប់បង្រៀនបងប្អូនដែលមកទទួលការអប់រំពីយើង។ ដូច្នេះ ឲ្យយើងត្រៀមខ្លួនដើម្បីបង្រៀន ត្រៀមខ្លួនដើម្បីទទួលការអប់រំថែមទៀត កុំឲ្យយើងមើលតែមេរៀនរបស់យើង។ "**អ្វីដែលបានលឺ និងដែលបានឃើញ**" មានន័យថាលោកប៉ូលមានសកម្មភាព ផ្តល់សក្ខីភាពសម្រាប់យើង យើងមិនមែនតែជាគ្រូអប់រំជំនឿ យើងជាគ្រីស្តបរិស័ទម្នាក់ ឲ្យយើងផ្តល់សក្ខីភាពអំពីជីវិតរបស់យើង មិនមែនតែរបៀបនិយាយ គឺទាំងរបៀបដែលយើងស្វាគមន៍ របៀបដែលយើងមានទំនាក់ទំនង របៀបដែលយើងលើកទឹកចិត្ត របៀបដែលយើងធ្វើដំណើរជាមួយបងប្អូនដែលកំពុងស្វែងរកព្រះជាម្ចាស់នៅក្នុងជីវិតផ្ទាល់ខ្លួន។ បន្តិចម្តងៗដូចលោកប៉ូលបាននិយាយថា "**ធ្វើដូច្នេះព្រះជាម្ចាស់ដែលជាប្រភពនៃសេចក្តីសុខសាន្តនឹងគង់ជាមួយបងប្អូនមិនខាន**" នេះជាគោលដៅនៃកម្មវិធីអប់រំជំនឿ គឺណែនាំឲ្យបងប្អូនមានបទពិសោធជាមួយព្រះជាម្ចាស់ផ្ទាល់។ ហេតុនេះហើយ នៅពេលយើងអប់រំ នៅពេលយើងផ្តល់សក្ខីភាព នៅពេលយើងណែនាំឲ្យគេឃើញ ឲ្យគេលឺអំពីជីវិតរបស់យើងជាគ្រីស្តបរិស័ទ ព្រះជាម្ចាស់ដែលជាប្រភពនៃសេចក្តីសុខសាន្តគង់នៅជាមួយបងប្អូន។ ជាអ្វីដែលគេចាំដប់ឆ្នាំ ម្ភៃឆ្នាំទៀត នៅពេលខ្ញុំអប់រំជំនឿ ខ្ញុំមានបទពិសោធអំពីព្រះជាម្ចាស់ ពេលខ្ញុំចូលនៅក្នុងព្រះវិហារ ខ្ញុំមានបទពិសោធអំពីព្រះជាម្ចាស់។ បន្តិចម្តងៗ បទពិសោធអំពីព្រះជាម្ចាស់ គឺណែនាំឲ្យយើងទទួលសេចក្តីសុខសាន្តនៅក្នុងដួងចិត្ត។

ថ្ងៃនេះ យើងគោរពសន្តប្រាំងស្វ័រនៃទីក្រុងអាស៊ីស៊ី ជាសន្តម្នាក់ដែលមនុស្សទូទាំងពិភពលោកនរណាក៏ស្គាល់គាត់ គាត់មានឥទ្ធិពលលើព្រះសហគមន៍ខ្លាំងមែនទែនអំពីរបៀបដែលគាត់រស់នៅ។ គាត់ជាយុវជនអ្នកមានម្នាក់នៅប្រទេសអ៊ីតាលី គាត់មានលុយច្រើន គាត់ដើរលេងច្រើន ក្រោយមកគាត់ចង់ធ្វើទាហាន ពេលធ្វើទាហានគាត់បានត្រូវរបួសសម្រាកព្យាបាលនៅមន្ទីរពេទ្យយ៉ាងយូរ។ នៅពេលនោះ គាត់ចាប់ផ្តើមគិតថា **តើកន្លងមកជីវិតរបស់ខ្ញុំមានន័យយ៉ាងដូចម្តេច?** គាត់បានគិតច្រើនរហូតដល់គាត់ចេញពីមន្ទីរពេទ្យ គាត់បានឃើញវិហារតូចមួយដែលកំពុងដួលរលំអស់គ្មានសល់។ នៅពេលនោះ គាត់បានលឺព្រះសូរសៀងរបស់ព្រះជាម្ចាស់ថា "**ប្រាំងស្វ័រអើយ! សូមជួយខ្ញុំដើម្បីកសាងព្រះសហគមន៍សាជាថ្មី**" គាត់បានភ្ញាក់ផ្អើលមែនទែន ណែនាំឲ្យគាត់គិតអំពីជីវិតសប្បាយៗរបស់គាត់ម្តងទៀត គាត់នឹកឃើញថាឥលូវនេះព្រះជាម្ចាស់មានព្រះបន្ទូលមួយពិសេសសម្រាប់ខ្ញុំ គឺឲ្យខ្ញុំទៅសាងសង់ព្រះវិហារនេះសាជាថ្មី។ ក្រោយមកគាត់សម្រេចចិត្តដល់ពេលវេលាកែប្រែចិត្តគំនិត គាត់បានទៅជួបលោកអភិបាលពេលនោះគាត់បាន

ដោះអាវរបស់គាត់ទៅឲ្យលោកអភិបាល ហើយយកក្រណាត់ពីឪពុករបស់គាត់ទៅលក់ ដើម្បីយកលុយជួយដល់អ្នកក្រីក្រ។ គាត់បានខិតខំយកថ្មដើម្បីកសាងព្រះវិហារនេះសាជាថ្មី ប៉ុន្តែសម័យនោះព្រះសហគមន៍នៅភ្ជាប់ជាមួយស្តេច ជាមួយរដ្ឋអំណាច ព្រះសហគមន៍ដូចជានៅឆ្ងាយពីប្រជារាស្ត្រតូចតាចអស់ហើយ។ ពេលសន្តហ្វ្រង់ស្វ័រដេកលក់ គាត់បានយល់សុបិនឃើញថា ព្រះវិហាររបស់សម្តេចប៉ាបនៅទីក្រុងរ៉ូមកំពុងដួលបន្តិចម្តងៗ ហើយគាត់ផ្ទាល់ខ្លួនបានខិតខំទ្រព្រះវិហារកុំឲ្យដួល។ នេះណែនាំឲ្យគាត់យល់ថា គាត់មិនត្រឹមតែត្រូវជួសជុលព្រះវិហារតូចនេះទេ ព្រះជាម្ចាស់ជ្រើសរើសគាត់ដើម្បីណែនាំឲ្យព្រះសហគមន៍មានរបៀបថ្មី។ គាត់បានប្រមូលយុវជនមួយចំនួន ដោយរស់នៅសាមញ្ញធម្មតាជាមួយអ្នកក្រីក្រ អ្នកតូចតាច។ នៅក្នុងជីវិតរបស់គាត់មានចំណុចពីរដែលសំខាន់ គឺទីមួយ **ភាតរភាព** គាត់បានបង្កើតឲ្យមានក្រុមបងប្រុសហ្វ្រង់ស៊ីសដែលចេះរស់នៅដូចជាបងប្អូនបង្កើត នៅក្នុងរបៀបធម្មតាបំផុត។ ទីពីរ **ជិតស្និទ្ធជាមួយធម្មជាតិ** ជាមួយអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើត គាត់មានទំនុកតម្កើងដែលគាត់បង្កើត ដោយកោតសរសើរព្រះចន្ទ ព្រះអាទិត្យ ដើមឈើ ផ្កា អ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើត។ សន្តហ្វ្រង់ស្វ័រ គាត់មានទំនាក់ទំនងពិសេសជាមួយសត្វទាំងឡាយ ជាមួយធម្មជាតិទាំងឡាយ ណែនាំឲ្យយើងស្រឡាញ់ធម្មជាតិដែលយើងបានទទួល។

សព្វថ្ងៃ ដែលយើងកំពុងបំផ្លាញធម្មជាតិអស់ហើយ សន្តហ្វ្រង់ស្វ័រទៅជាគំរូមួយ ដើម្បីឲ្យយើងស្រឡាញ់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ ដើម្បីឲ្យយើងបង្កើតក្រុមគ្រួសារតែមួយ។ សម្រាប់យើងដែលជាគ្រូអប់រំជំនឿ ថ្ងៃបុណ្យសន្តហ្វ្រង់ស្វ័រ ជាឱកាសមួយដើម្បីនឹកឃើញរបៀបដែលសន្តហ្វ្រង់ស្វ័របានបង្កើតទំនាក់ទំនងសាមញ្ញមែនទែន ជាមួយបងប្អូន ជាមួយធម្មជាតិ និងណែនាំឲ្យគាត់មានឥទ្ធិពលទាំងក្នុងព្រះសហគមន៍ ទាំងក្នុងសង្គមអស់រយៈពេល៨០០ឆ្នាំកន្លងមក។ ដូច្នេះ សម្រាប់យើងដែលជាគ្រូអប់រំជំនឿឲ្យយើងដឹងថា ប្រហែលមេរៀនដែលយើងបង្រៀនគេអាចភ្លេចអស់ហើយ ប៉ុន្តែរបៀបដែលយើងបានយកចិត្តទុកដាក់ របៀបដែលយើងបានស្រឡាញ់គេ របៀបដែលយើងបានស្រឡាញ់ព្រះជាម្ចាស់ របៀបដែលយើងបានអធិដ្ឋាន ណែនាំឲ្យគេចងចាំអស់មួយជីវិត។

យើងអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ ដើម្បីឲ្យព្រះសហគមន៍របស់យើងតាមរយៈកម្មវិធីអប់រំជំនឿ ទៅជាព្រះសហគមន៍ដែលផ្តល់សក្ខីភាពអំពីធម៌មេត្តាករុណា អំពីសង្គមថ្មីដែលយើងចង់បង្កើតជាសង្គមថ្មីដែលពោរពេញដោយសេចក្តីសុខសាន្ត។ ប្រសិនបើ យើងមិនចេះស្វាគមន៍ព្រះយេស៊ូផ្ទាល់នៅក្នុងជីវិតរបស់យើង ព្រះអង្គទៅកន្លែងផ្សេង ដូចយើងបានស្តាប់ក្នុងគម្ពីរដំណឹងល្អថា "**ហេតុនេះហើយ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថាព្រះជាម្ចាស់នឹងដកព្រះរាជ្យចេញពីអ្នករាល់**

**គ្នា ប្រគល់ទៅឲ្យសាសន៍មួយទៀតដែលចេះបង្កើតផលសមស្របនឹងព្រះរាជ្យ**” ដូច្នេះទ្រព្យសម្បត្តិដែលយើងបានទទួលឲ្យយើងថែរក្សា កុំឲ្យយើងមើលងាយទ្រព្យនេះ កុំឲ្យព្រះជាម្ចាស់ដកចេញពីដៃយើងឲ្យទៅអ្នកផ្សេង។ យើងអធិដ្ឋាន សូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើងជានិច្ច ឲ្យយើងកសាងព្រះសហគមន៍និងព្រះរាជ្យរបស់ព្រះជាម្ចាស់។ អាម៉ែន៕